# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 14 PR-17/EoJ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧

## ពិធីបើកសម្ពោធមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយ ដែលទីស្តីការគណៈរដ្ឋមន្ត្រីនឹងរៀបចំ ពិធីបើកសម្ពោធមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង៩:០០។

ប្រទេសជប៉ុន បានផ្តោតសារៈសំខាន់យ៉ាងខ្លាំង ទៅលើសាលាក្តីខ្មែរក្រហម ដោយបានផ្តល់ជំនួយហិរញ្ញវត្ថុ និងបុគ្គលិកដល់សាលាក្តីតាំងពីពេលចាប់ផ្តើមដំបូង ហើយក៏ជាម្ចាស់ជំនួយធំជាងគេរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ជាមួយគ្នានេះ យើងជឿជាក់យ៉ាងមុតមាំថា មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់មានតំលៃដ៏ធំធេងក្នុងការអភិរក្សកេរ្តិ៍ដំណែលនៃសាលាក្តីខ្មែរក្រហម។ ប្រទេសជប៉ុនបានបរិច្ចាគថវិកាប្រហែល 2,354,000 ដុល្លារសហរដ្ឋអាមេរិក តាមរយៈថវិកាបដិភាគរបស់ជប៉ុន ដែលបានមកពី ជំនួយឥតសំណងក្រៅគម្រោងរបស់ជប៉ុន (Japanese Non-Project Grant Aid) សម្រាប់ការសាងសង់អគារ និងគ្រឿងបរិក្ខារប្រើប្រាស់របស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដែលរួមមាន បណ្ណសារដ្ឋាន និងឧបករណ៍ទំនាក់ទំនង និងព័ត៌មាន។ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់បានរក្សាទុកនូវឯកសារជាប្រភេទបោះពុម្ព និងទិន្នន័យក្នុងកុំព្យូទ័រដែលទាក់ទងទៅនឹងដំណើរការនៃសាលាក្តីខ្មែរក្រហម។ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់នឹងជួយអោយប្រជាជនកម្ពុជា និងជនបរទេសដែលរួមមាន អ្នកស្រាវជ្រាវ មេធាវី និងសិស្សនិស្សិតដែលមានចំណាប់អារម្មណ៍នឹងសាលាក្តី អាចទទួលបានឯកសារទាំងអស់នេះ។ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់នឹងដើរតួនាទីជានិមិត្តរូបនៃការចង់ចាំ និងការមិនអោយកើតមានឡើងវិញនូវរបបខ្មែរក្រហម។

យើងសង្ឃឹមថា មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់នឹងត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋគ្រប់លំដាប់។

ប្រសិនបើលោកអ្នកមានសំនួរពាក់ព័ន្ធនឹងព័ត៌មានលម្អិតនៃពិធីបើកសម្ពោធនេះ សូមទាក់ទង:

មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
អាស័យដ្ឋាន៖ ផ្លូវលេខ១១២៩ & ១១៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: +855 12 400 741 / 95 752 969
អ៊ីម៉ែល: Info@ldc-eccc.gov.kh